ធ៧ ០០- ០៥ ប្រក

# ប្រកាស

## ស្តីពី

## ការផ្តល់អាជ្ញាប័ណ្ណចំពោះធនាគារឯកទេសឥណទានជនបទ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## សំ រេ ច

## ជំពូក ទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ធនាគារឯកទេសឥណទានជនបទ តទៅនេះហៅថាធនាគារឯកទេស ដូចមានកំណត់និយមន័យក្នុងជំពូកទី ១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុត្រូវទទួលអាជ្ញាប័ណ្ណពីធនាគារ ជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមធ្វើប្រតិបត្តិការអនុលោមតាម មាត្រា ១៤ នៃច្បាប់ដដែលនេះ ។

**ប្រការ ២.-**

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវធ្វើតែប្រតិបត្តិការណាដែលមានបញ្ជាក់ច្បាស់តាមខ្លឹមសារនៃលិខិតអនុញ្ញាត ។

**ប្រការ ៣.-**

អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណសំរាប់ធនាគារឯកទេសត្រូវប្រកាន់យកនូវរូបភាពគតិយុត្តណាមួយក្នុងចំណោមរូបភាព គតិយុត្តដែលមានចែងក្នុងជំពូកទី ៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៤.-**

ធនាគារឯកទេស ត្រូវមានដើមទុនអប្បបរមាចុះក្នុងលក្ខន្តិកៈចំនួនដប់ពាន់លានរៀល (១០.០០០.០០០.០០០ រៀល) ។

## ជំពូក ទី ២
## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាប័ណ្ណ

**ប្រការ ៥.-**

ពាក្យសុំអាជ្ញាប័ណ្ណ ត្រូវស្នើដោយបុគ្គល ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវ( អ្នកចាត់ការឬជនដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ) ស្របតាមបញ្ញត្តិដែលមានរៀបរាប់ខាងក្រោមនេះ ÷

ក- នាម ឬ នាមករណ៍អាជីវកម្មរបស់គ្រឹះស្ថាន

ខ- អាសយដ្ឋាននៃទីស្នាក់ការកណ្តាលដែលបានចុះបញ្ជី

គ- រូបភាពគតិយុត្តនិងលក្ខន្តិកៈ ឬឯកសារបង្កើតផ្សេងៗទៀត

ឃ- ប្រភេទមូលប័ត្រតំណាងអោយដើមទុន ។ ចំណងទាក់ទងរវាងការកាន់កាប់មូលប័ត្រទាំងនោះនិងការអនុវត្តន៍សិទ្ធិបោះឆ្នោត

ង- ចំនួនដើមទុនផ្ទាល់ដែលបានអនុញ្ញាតនិងដែលបានបង់

ច-	ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោតនិង កិច្ចព្រមព្រៀងដែលអាចមានរវាង ភាគទុនិកៈដែលដើរតួនាទីក្នុងការដឹកនាំគោលនយោបាយរបស់ធនាគារ

ឆ-	ភាគទុនិកៈដែលកាន់កាប់R ប៉ាំភាគរយ (៥%) នៃសិទ្ធិបោះឆ្នោតឬលើសពីនេះត្រូវផ្តល់ ពតិមានដូចមានរៀបរាប់ក្នុងប្រការ ៦ នៃប្រកាសនេះ

ជ-	អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិចបំផុតពីររូប(២រូប)ដែលទទួលខុសត្រូវក្នុងការដឹកនាំ ដោយមានប្រសិទ្ធិភាពនូវសកម្មភាពអាជីវកម្មរបស់ធនាគារឯកទេស ។

អ្នកចាត់ការដែលត្រូវបានតែងតាំងដោយអ្នកមានសមត្ថកិច្ច ត្រូវបំពេញ ជីវប្រវត្តិ និងសំនួរដូចមានក្នុងឧបសម្ព័ន្ធទី ២ ហើយ ត្រូវផ្តល់នូវលិខិតថ្កោលទោស

ឈ-	អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងដោយ បន្ថែមពីលើពតិមានខាងលើត្រូវ មានជីវប្រវត្តិ ព្រមទាំងត្រូវមានរបាយការណ៏បញ្ជាក់ថា គ្មាននរណាម្នាក់ពាក់ព័ន្ធទៅនឹង ការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវមាន បទពិសោធន៏ខាងឥណទានយ៉ាងតិចបំផុតបីឆ្នាំ (៣ឆ្នាំ)

ញ-	ប្រសិនបើនីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណគឺជាអង្គភាពដែលបានបង្កើតរួច ហើយ ត្រូវផ្តល់មកជាមួយនូវការអធិប្បាយអំពីមុខរបររបស់ខ្លួនព្រមទាំងតារាងតុល្យការ ដែលមានការបញ្ជាក់ពីស្នងការគណនី សំរាប់ប្រតិបត្តិការក្នុងរយៈពេលបីឆ្នាំ (៣ឆ្នាំ) ចុង ក្រោយ

ដ-	ការពិពណ៌នាពីផែនការសកម្មភាពអាជីវកម្មរយៈពេលបីឆ្នាំ (៣ឆ្នាំ) ទៅមុខ ÷

- ទំហំនៃការអោយខ្ចីគ្រប់ប្រភេទដែលអាចមាននៅក្នុងឬក្រៅតារាងតុល្យការនិងសេវា ផ្សេងៗទៀតដែលត្រូវផ្តល់អោយអតិថិជនឬសមាជិក(ចំពោះឥណទាន ប្រភេទ ទំរង់ គោលបំណង ខ្ចីមសារ និងល័ក្ខខ័ណ្ឌចំបងៗ ផលកំរៃដែលទទួលបានប្រចាំឆ្នាំនិងទឹក ប្រាក់មិនទាន់សង)
- ប្រភេទអតិថិជនដែលធនាគារឯកទេសមានបំណងប្រាស្រ័យទាក់ទង
- ប្រភពធនធានហិរញ្ញវត្ថុដែលបានគ្រោងទុក ÷ មូលនិធិផ្ទាល់ R បាក់ឧបត្ថម្ភ បំណុល

បន្ទាប់ បន្សំ Rបាក់បញ្ញើ Rបាក់កម្ចី ជាដើម ហើយបើចាំបាច់ត្រូវបញ្ជាក់ច្បាស់ពីដើម

កំណើតនិងកម្មសិទ្ធិនៃធនធានទាំងនេះក្នុងករណីមិនប្រាកដ( បំណុលបន្ទាប់បន្សំជាដើម)

- ចំនួនប្រហាក់ប្រហែលនៃនិយោជិតក្នុងរយៈពេលបីឆ្នាំ( ៣ឆ្នាំ) ខាងមុខ និងបញ្ជីបើកបៀវត្សដោយរាយលំអិតតាមប្រភេទបុគ្គលិក
- ទីតាំងសាខាដែលមានស្រាប់ឬដែលគ្រោងអោយមាន
- ការចាត់តាំងនិងធនធាន ដែលបានគ្រោងទុក ពិសេសចំពោះទំរង់ការគណនេយ្យ និងឧបករណ៍កុំព្យូទ័r
- តារាងតុល្យការនិងការព្យាករណ៍គណនីខាត-ចំណេញសំរាប់ការិយបរិច្ឆេទគណនេយ្យបីឆ្នាំ ( ៣ឆ្នាំ) ខាងមុខ ។ ត្រូវព្យាករណ៍ក៏រិតអនុបាតប្រុងប្រយ័ត្នចំបង៧(ដូចបានកំណត់ដោយ ធនាគារជាតិនៃកម្ពុជា) នៅខាងចុង ការិយបរិច្ឆេទគណនេយ្យបីឆ្នាំ (៣ឆ្នាំ)ខាងមុខ

ឋ- ការត្រួតពិនិត្យផ្ទៃក្នុង ÷

- ការចាត់តាំងផែនការត្រួតពិនិត្យបញ្ជីផ្ទៃក្នុងដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- អត្តសញ្ញាណរបស់ស្នងការគណនីឯករាជ្យដែលបានជ្រើសរើសពីបញ្ជីប្រតិស្រុតិ
- ប្រភេទនៃមុខងារដែលត្រូវប្រគល់អោយស្នងការគណនីឯករាជ្យនោះ ។

## ប្រការ ៦._

ភាគទុនិកៈដែលកាន់កាប់Rបាំភាគរយ(៥%)ឬលើសពីនេះនៃដើមទុនឬនៃសិទ្ធិបោះឆ្នោតរបស់អ្នកស្នើសុំត្រូវផ្តល់ពតិមានដូចតទៅ ÷

ក- អត្តសញ្ញាណរបស់ភាគទុនិកៈ ÷

ក្នុងករណីជានិតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋានទីស្នាក់ការកណ្តាល និងលក្ខន្តិកៈ ។

ក្នុងករណីជាឯកត្តជន ត្រូវរៀបរាប់ នាម គោត្តនាម ថ្ងៃខែឆ្នាំនិងទីកន្លែងកំណើត សញ្ជាតិ និងលំនៅដ្ឋាន ។ ត្រូវបញ្ជាក់ថា តើបុគ្គលនេះត្រូវបានតែងតាំងជាអ្នកចាត់ការមួយរូបរបស់ ធនាគារឬទេ ។ ត្រូវប្រាប់ថា តើភាគទុនិកៈជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានឬទេ ។ បើមែន ត្រូវធានាថា សមាជិកនោះមិនមានពាក់ព័ន្ធជាមួយការហាមឃាត់ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទេ

ខ- បញ្ជាក់ពីចំនួននិងភាគរយនៃភាគកម្មដែលបានស្នើនិងចំនួននិងភាគរយនៃសិទ្ធិបោះឆ្នោត ។ រៀបរាប់លំអិតពីការសំរបសំរួលខាងគតិយុត្តិនិងខាងហិរញ្ញវត្ថុ ចំពោះការទទួលយកមូលប័ត្រ ។ បង្ហាញថា តើសកម្មភាពប្រតិបត្តិការស្ថិតនៅក្រោមចំណុះនីតិវិធីដោយឡែកដែលអនុវត្ត ចំពោះការវិនិយោគបរទេសនៅកម្ពុជាឬទេ ហើយតើទំរង់បែបបទទាំងនេះត្រូវបានបំពេញហើយឬនៅ

គ- រៀបរាប់ពីសកម្មភាពរបស់ភាគទុនិកៈ ។ ប្រសិនបើភាគទុនិកៈជាសមាជិកនៃក្រុមមួយ ត្រូវពិពណ៌នាពីអង្គភាពធំៗនៃក្រុមនោះរួមជាមួយអង្គការលេខផង ។ ត្រូវបញ្ជាក់ផងថា តើភាគទុនិកៈមាន ទ្រព្យសម្បត្តិច្រើននៅក្នុងស្ថាប័នឥណទានផ្សេងៗទៀតឬទេ បញ្ជាក់ថា តើក្រុមដែលជាកម្មសិទ្ធិផ្ទាល់របស់ភាគទុនិកៈមានទុនច្រើននៅក្នុងគ្រឹះស្ថានឥណទាន ឬទេ ។ បើមានត្រូវរៀបរាប់អោយអស់

ឃ- Rបាប់ថា
តើភាគទុនិកៈនិងក្រុមហ៊ុនដែលអាចបញ្ចូលជាមួយគ្នាមានធ្វើសកម្មភាពហិរញ្ញវត្ថុ
ឬទេ ។ បើមាន ត្រូវបញ្ជាក់ថា ក្រុមហ៊ុនទាំងនោះស្ថិតក្រោមចំណុះបទបញ្ជាណាឬអាជ្ញាធរណា

ង- បញ្ជាក់ពីបែបបទនៃការត្រួតពិនិត្យផ្ទៃក្នុងនិងពីខាងក្រៅរបស់ភាគទុនិកៈ

ច- បញ្ជាក់ថា តើក្នុងរយៈពេលដប់ឆ្នាំ (១០ឆ្នាំ) កន្លងមក ភាគទុនិកៈបានទទួលរងនូវការស៊ើបអង្កេតឬទទួលរងនូវការពិន័យជាសំភារៈតាមទំរង់ការវិជ្ជាជីវៈ រដ្ឋបាលឬតុលាការ ឬទេ

ឆ- Rបាប់ពីគោលដៅរបស់ភាគទុនិកៈ
ក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងធនាគារដែល
បានដាក់ពាក្យសុំអាជ្ញាប័ណ្ណនិងផ្តល់ពត៌មានដែលពាក់ព័ន្ធទាំងអស់

ជ-  បញ្ជាក់ថា តើមានទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិកៈនិងអ្នកស្នើសុំឬទេ ហើយតើទំនាក់ទំនងទាំងនេះនឹងត្រូវបានពង្រីកទៅអនាគតយ៉ាងណា

ឈ-  បញ្ជាក់ថា តើទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងធនាគាររបស់ភាគទុនិកៈនៅកម្ពុជា មានអ្វីខ្លះ ហើយទំនាក់ទំនងទាំងនេះនៅមានរហូតដល់ពេលណាទៀត ។

**ប្រការ ៧.-**

ភាគទុនិកៈដែលកាន់កាប់ដោយផ្ទាល់ឬប្រយោលយ៉ាងតិចបំផុតម្ភៃភាគរយ(២០%)នៃដើមទុនឬនៃសិទ្ធិបោះឆ្នោត ត្រូវបានចាត់ទុកថាជាភាគទុនិកៈមានឥទ្ធិពលស្របតាមមាត្រា ២៦ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ភាគទុនិកៈមានឥទ្ធិពលត្រូវបានធនាគារជាតិនៃកម្ពុជាតំរូវអោយបង្កើនមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ សំរាប់គោលបំណងនោះ ត្រូវផ្ញើលិខិតដូចមានគំរូនៅក្នុងឧបសម្ព័ន្ធ ទី៣ ទៅទេសាភិបាលធនាគារជាតិនៃកម្ពុជា ។

បទបញ្ញានេះអាចត្រូវដកចេញវិញបាន តែនៅពេលបានបង្កើតអោយមានការធានារ៉ាប់រងលើប្រាក់បញ្ញើនៅកម្ពុជា ។

ក្រៅពីនេះយោងតាមមាត្រា ៤០ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាអាចលើកលែងជាលាយលក្ខណ៏អក្សរ អនុញ្ញាតអោយរួចផុតពីការអនុវត្តន៏មាត្រា ៧ នៅពេលអនុម័តលើអាជ្ញាប័ណ្ណ ។

## ជំពូក ទី ៣
## ការអនុមតិផ្តល់អាជ្ញាប័ណ្ណ និង ការយកកំរៃ

**ប្រការ ៨.-**

ធនាគារជាតិនៃកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខណ៏អក្សរអំពីការសំរេចរបស់ខ្លួនក្នុងរយៈពេលប្រាំមួយខែ(៦ខែ) ចាប់ពីពេលទទួលពាក្យស្នើសុំអាជ្ញាប័ណ្ណ រួមទាំងឯកសារដែលពាក់ព័ន្ធទាំងអស់ផង ។ នៅពេល ណាមានការចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់ចេញនូវល័ក្ខខ័ណ្ឌនិងរយៈពេលនៃការអនុវត្តន៏

លិខិតអនុញ្ញាត ។ ប្រសិនបើអនុវត្តនពុំបានតាមពេលវេលាកំណត់ខាងលើ លិខិតអនុញ្ញាតនេះត្រូវចាត់ទុកជាមោឃៈ លើកលែងតែមានការស្នើសុំពន្យារពេលនិងមានការយល់ព្រមពីធនាគារជាតិនៃកម្ពុជា។

**ប្រការ ៩.-**

អាជ្ញាប័ណ្ណមានសុពលភាពសំរាប់រយៈពេលបីឆ្នាំ (៣ឆ្នាំ) គិតចាប់ពីពេលបានចេញអោយ ។ អាជ្ញាប័ណ្ណនេះអាចស្នើសុំបន្តជាថ្មីបាន លុះត្រាណាតែរាល់ការប្រព្រឹត្តិល្មើសច្បាប់និងបទបញ្ជាត្រូវបានដោះស្រាយ ។ ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណជាថ្មីត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងយឺតបំផុត បីខែ(៣ខែ) មុនពេលផុតសុពលភាពនៃអាជ្ញាប័ណ្ណដែលកំពុងប្រើប្រាស់ ។

ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្តតាមកាលកំណត់ខាងលើនេះទេ ធនាគារសាមីត្រូវទទួលរងការផាកពិន័យជាប្រាក់មួយរយពាន់រៀល(១០០.០០០ រៀល) ក្នុងមួយថ្ងៃ រហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំនេះ ។

**ប្រការ ១០.-**

អ្នកស្នើសុំត្រូវបង់សោហ៊ុយសិក្សាសំណុំលិខិតចំនួនប្រាំរយពាន់រៀល (៥០០.០០០ រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ ។

**ប្រការ ១១.-**

ធនាគារឯកទេសត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំចំនួនដប់លានរៀល(១០.០០០.០០០ រៀល) ចំពោះទីស្នាក់ការ កណ្តាលនិងប្រាំបីលានរៀល (៨.០០០.០០០ រៀល) ចំពោះសាខានិមួយៗរបស់ធនាគារឯកទេសនៅមុន ថ្ងៃទី ១៥ ខែ មករា រៀងរាល់ឆ្នាំ ។ ចំពោះធនាគារដែលបានបង្កើតឡើងក្នុងឆ្នាំ សោហ៊ុយអាជ្ញាប័ណ្ណត្រូវ បានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ ។ ក្នុងករណីមានការយឺតយ៉ាវ ក្នុងការបង់សោហ៊ុយអាជ្ញាប័ណ្ណ ធនាគារដែលពាក់ព័ន្ធត្រូវទទួលរងនូវការផាកពិន័យ ដោយបង់ការប្រាក់ លើទឹកប្រាក់ដែលនៅ មិនទាន់បានបង់ តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមានក្នុងរយៈពេល រហូតដល់ សាមសិបថ្ងៃ (៣០ថ្ងៃ) ។ បើនៅតែពុំអាចបង់សោហ៊ុយអាជ្ញាប័ណ្ណបាន ធនាគារសាមីត្រូវរងទណ្ឌកម្មធ្ងន់ជាងនេះទៀត រហូតដល់ត្រូវដកហូតអាជ្ញាប័ណ្ណ ។

# ជំពូក ទី ៤
# បទបញ្ញាប្រុងប្រយ័ត្ន

## ប្រការ ១២.-

អ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណដែលពុំធ្លាប់ធ្វើប្រតិបត្តិការ ត្រូវបង់បង្គ្រប់អោយពេញមួយរយភាគរយ (១០០%) នៃដើមទុនចុះបញ្ជីក្នុងលក្ខន្តិកៈក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា នៅមុន ពេលចាប់ ផ្តើមធ្វើប្រតិបត្តិការ ។

## ប្រការ ១៣.-

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណហើយ ត្រូវរក្សាប្រាក់តំកល់ធានាលើដើមទុនស្មើនឹងប្រាំភាគរយ (៥%) ដោយគ្មានការប្រាក់នៃដើមទុនដែលបានចុះបញ្ជីនៅក្នុងគណនីដែលបានបើកនៅធនាគារជាតិ នៃកម្ពុជា ។

ធនាគារជាតិនៃកម្ពុជា នឹងទូទាត់សងប្រាក់តំកល់ធានាលើដើមទុននេះទៅអោយធនាគារឯកទេសវិញ តែនៅពេលធនាគារនោះត្រូវបានជំរះបញ្ជីដោយស្ម័គ្រចិត្តនិងគ្មានប្រាក់បញ្ញើនៅខាងទ្រព្យអកម្ម ។

## ប្រការ ១៤.-

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណហើយត្រូវតំកល់ទុនបំរុងកាតព្វកិច្ចR ប៉ាំភាគរយ (៥%) នៃប្រាក់ បញ្ញើ ដែលបានទទួលពីអតិថិជន នៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា ។ Tun បំរុងកាតព្វកិច្ចនេះ ត្រូវបានរក្សាទុកតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងបទបញ្ញាដោយឡែកស្តីពីទុន បំរុងកាតព្វកិច្ច ។

## ប្រការ ១៥.-

ធនាគារឯកទេសដែលបានទទួលអាជ្ញាប័ណ្ណរួចហើយ ត្រូវអនុវត្តអោយបានសមស្របតាមបញ្ញត្តិទាំងអស់ដែលធនាគារត្រូវអនុវត្ត ពិសេសតំរូវការនៃការធ្វើរបាយការណ៍ ។

## ជំពូក ទី ៥
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ១៦.-**

សេចក្ដីជូនដំណឹងទាក់ទងដល់ការទទួលបានឬការបាត់បង់ទៅវិញនូវភាគហ៊ុន ក្នុងក្របខ័ណ្ឌនៃមាត្រា ២៣ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានបញ្ចូលការពិពណ៌នាពីមូលហេតុផ្សេងៗ សំរាប់ សកម្មភាពប្រតិបត្តិការនិងគោលដៅដែលត្រូវអនុវត្តតាម ។

ឯកសារជូនដំណឹងក៏ត្រូវមានពត៌មានដូចមានបញ្ជាក់ក្នុងប្រការ ៦ ខាងលើស្ដីពីភាគទុនិកៈដែលពាក់ព័ន្ធ ។

ធនាគារពាក់ព័ន្ធត្រូវបង់សោហ៊ុយផ្ទេរហ៊ុនចំនួនមួយភាគរយ (១%) លើចំនួនប្រាក់ហ៊ុនដែលត្រូវបានផ្លាស់ប្ដូរ ។

**ប្រការ ១៧.-**

ការអនុញ្ញាតចំពោះពាក្យស្នើសុំទាក់ទងដល់ការទទួលបានឬការបាត់បង់ទៅវិញនៃភាគហ៊ុនក្នុងក្របខ័ណ្ឌនៃមាត្រា ២៤ នៃច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវមានបញ្ចូលការពិពណ៌នាពីមូលហេតុ ផ្សេងៗសំរាប់សកម្មភាពប្រតិបត្តិការនិងគោលដៅដែលត្រូវអនុវត្តតាម ។

ឯកសារស្នើសុំក៏ត្រូវមានពត៌មានដូចមានបញ្ជាក់ក្នុងប្រការ ៦ ខាងលើ ស្ដីពីភាគទុនិកៈដែលពាក់ព័ន្ធ ។ ភាគទុនិកៈដែលមានបំណងកាន់កាប់ដោយផ្ទាល់ឬដោយប្រយោលយ៉ាងតិចបំផុតម្ភៃភាគរយ(២០%) នៃដើមទុនឬ នៃសិទ្ធិបោះឆ្នោត ត្រូវធ្វើប្រតិវេទន៍ ស្របតាមគំរូដែលមានក្នុងឧបសម្ព័ន្ធ ទី១ ។ ជាងនេះទៀត ធនាគារឯកទេសពាក់ព័ន្ធត្រូវបង់សោហ៊ុយចំនួនមួយភាគរយ(១%)លើចំនួនប្រាក់ដែលត្រូវបានផ្លាស់ប្ដូរ ។

**ប្រការ ១៨.-**

ក្នុងករណីតែងតាំងអ្នកចាត់ការថ្មី (គឺបុគ្គលពីររូប ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រតិបត្តិការធនាគារអោយមានប្រសិទ្ធិភាព) ត្រូវផ្ដល់ពត៌មានដូចខាងក្រោមនេះទៅធនាគារជាតិនៃកម្ពុជា ÷

- ឯកសារជាភស្តុតាងបញ្ជាក់ពីការតែងតាំង （មានជាអាទិ៍កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល）
- ជីវប្រវត្តិនិងការបំពេញសំនួរក្នុងឧបសម្ព័ន្ធទី ២

ឯកសារទាំងអស់នេះត្រូវតែផ្តល់អោយយ៉ាងហោចណាស់មួយខែមុនការចូលកាន់តំណែងរបស់បុគ្គល ដែលត្រូវបានតែងតាំង ។

**ប្រការ ១៩.-**

ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពគតិយុត្តឬស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ត្រូវតែដាក់ជូនធនាគារជាតិនៃកម្ពុជាដើម្បីសុំការយល់ព្រម ។ ឯកសារស្នើសុំត្រូវមានភ្ជាប់មកជាមួយនូវការរៀបរាប់ពីមូលហេតុនៃ ផែនការប្រតិបត្តិការ ហើយផ្អែកតាមករណី និមួយៗ ត្រូវមានភ្ជាប់នូវពតិមានដូចតទៅ ÷

- ការពង្រីកឬការកំណត់ឡើងវិញនូវសកម្មភាព ÷ ត្រូវផ្តល់ពតិមានដែលមានកំណត់ក្នុងកថាខ័ណ្ឌ ដ ប្រការ ៥ នៃប្រកាសនេះ
- ការបន្ថយដើមទុន ÷ ការពិពណ៌នាពីខ្លឹមសារនិងល័ក្ខខ័ណ្ឌដូចជាការសំរបសំរួលខាងគតិយុត្តិនិងខាងគណនេយ្យព្រមទាំងការកំណត់ច្បាស់នូវចំនួនថ្មីនៃមូលនិធិផ្ទាល់ដែលអាចមានឥទ្ធិពលទៅលើអាជីវកម្មទៅអនាគតនិងទៅលើអនុបាតប្រុងប្រយ័ត្ន
- ការផ្លាស់ប្តូររូបភាពគតិយុត្ត ÷ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិកៈនិងពតិមានទាក់ទងដល់អង្គភាពគ្រប់គ្រង
- ការផ្លាស់ប្តូរនាមករណ៏អាជីវកម្ម ÷ សេចក្តីព្រាងវិសោធនកម្មលក្ខន្តិកៈ

រាល់ការផ្លាស់ប្តូរទាំងអស់ត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជាយ៉ាងយឺតបំផុតបីខែ（៣ខែ）មុនពេលអនុវត្តដើម្បីសុំការយល់ព្រម

ធនាគារត្រូវបង់សោហ៊ុយចំនួនមួយលានរៀល（១.០០០.០០០ រៀល ）ក្នុងមួយទំព័រនៃ លក្ខនិកៈដែលរងវិសោធនកម្ម ។

ធនាគារត្រូវបង់សោហ៊ុយបន្ថយដើមទុនចំនួនមួយភាគរយ（១%）លើចំនួនដែលបន្ថយ ។

**ប្រការ ២០.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២១.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារឯកទេសនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឹងម៉ាត់នូវ ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ២២.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ខែ មករា ឆ្នាំ ២០០០

**ទេសាភិបាល**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ២១

" ដើម្បីអនុវត្ត "

- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល

ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាបជាពតិមាន "

- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

## ឧបសម្ព័ន្ធ ទី ១

គំរូលិខិតត្រូវផ្ញើជូនឯកឧត្តមទេសាភិបាល ដែលត្រូវចុះហត្ថលេខាដោយអ្នកផ្តល់វិភាគទានកាន់កាប់ដោយផ្ទាល់ឬប្រយោលនូវដើមទុនឬសិទ្ធិបោះឆ្នោត ម្ភៃភាគរយ (២០%) ឬច្រើនជាងរបស់គ្រឹះស្ថាន ។

ក្នុងនាមខ្លួនខ្ញុំជា ( ត្រូវផ្តល់នូវស្ថានភាពរបស់អ្នកចុះហត្ថលេខា ) ខ្ញុំសូមជូនភ្ជាប់មកជាមួយនេះនូវពត៌មានតាមសំណើរបស់ធនាគារជាតិនៃកម្ពុជា ( លិខិតលេខ........) ទាក់ទងដល់ការកាន់កាប់ដើមទុនដែល ( ឈ្មោះរបស់អ្នកផ្តត់ផ្គង់វិភាគទាន ) មានបំណងចូលរួមក្នុង ( ឈ្មោះគ្រឹះស្ថាន ) ។

ខ្ញុំសូមបញ្ជាក់នៅក្នុងលិខិតនេះថា  ពត៌មាននេះគ្រប់គ្រាន់និងត្រឹមត្រូវហើយតាមការយល់ដឹងដ៏ប្រសើរបំផុតរបស់ខ្ញុំ  ពុំមានឯកសារបញ្ជាក់ការពិតណាផ្សេងពីនេះទៀតដែលត្រូវផ្តល់ជូន ធនាគារជាតិនៃកម្ពុជា ទៀតទេ  ។

ខ្ញុំសូមសន្យាផ្តល់ពត៌មានយ៉ាងឆាប់រហ័សជូនធនាគារជាតិនៃកម្ពុជា នូវរាល់ការប្រែប្រួលណាដែលធ្វើអោយប្លែកយ៉ាងខ្លាំងពីពត៌មានដែលបានផ្តល់ជូនរួចមកហើយ  ។

ខ្ញុំបានធ្វើការកត់សំគាល់ទៅលើបញ្ញត្តិនៃមាត្រា ២៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលបានចែងថា នៅពេលណាស្ថានភាពតំរូវហើយនោះ ធនាគារជាតិនៃកម្ពុជាអាចស្នើអោយភាគទុនិកៈដែលមាន ឥទ្ធិពលរបស់គ្រឹះស្ថានផ្តល់នូវការគាំទ្រដល់គ្រឹះស្ថាននោះ  ។

ដោយសេចក្តីគោរព

ហត្ថលេខា